Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |

# 2012 PUBLIC EXAMINATION

# Khmer

## Continuers Level

**Tuesday 16 October: 2 p.m. Eastern Standard Time**

Reading Time: 10 minutes
Writing Time: 2 hours and 50 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 50 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet in blue or black ink or ball-point pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2012

www.theallpapers.com

**Part A** (Questions 1 to 4)
(20 marks)

---

*When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear FOUR texts. Each text will be played twice. There will be a short break between the first and second playings in which you may make notes.

Listen carefully to each text and then answer the questions in ENGLISH.

**Marks** | You may make notes in this space.

**Text 1**

1. Why did Nary call Socheat? **2**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________



www.theallpapers.com

Marks

You may make notes in this space.

**Text 2**

2. (a) What advice does Sary's father give her? **4**

(b) What evidence in the text shows that Sary's father cares about her well-being? **3**



PLEASE TURN OVER

www.theallpapers.com

Marks

You may make notes in this space.

**Text 3**

3. (a) What is the purpose of this text? **2**

(b) Why does the speaker say that Chanthy's story is fascinating? **2**

(c) According to the speaker, why is music from the 1960s and early 1970s significant for Cambodians? **2**



www.theallpapers.com

Marks | You may make notes in this space.

**Text 4**

4. (a) What is Phare Ponleu Selpak? **1**

(b) How has Phare Ponleu Selpak helped Bunthorn? **2**

(c) How is Phare Ponleu Selpak funded? **2**



PLEASE TURN OVER

www.theallpapers.com

**Part B** (Questions 5 to 6)
(10 marks)

---

*When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:*

- *understand general and specific aspects of texts by identifying and analysing information;*
- *convey the information accurately and appropriately.*

---

You will hear TWO texts, one relating to Question 5 and one relating to Question 6. Each text will be played twice. There will be a short break between the first and second playings in which you may make notes.

Listen carefully to each text and then answer the questions in KHMER.

**Marks** | You may make notes in this space.

**Text 5**

5. (a) What does Samnarng want to do, and why? **2**

តើសំណាងចង់ធ្វើអ្វី ហើយហេតុអ្វី?

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

(b) How does Samnarng's mother feel about his plan? **2**

តើម្ដាយរបស់សំណាងមានអារម្មណ៍យ៉ាងណាដែរចំពោះគំរោងការរបស់វា?

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________



www.theallpapers.com

Marks | You may make notes in this space.

(c) Why does Samnarng's mother refer to the Khmer proverb? **1**

ហេតុអ្វីបានជាម្ដាយសំណាងយោងទៅសុភាសិតខ្មែរ?

___

___

___



www.theallpapers.com

Marks

You may make notes in this space.

**Text 6**

6. (a) According to Mr Sam, what issues and problems (apart from language) did Khmer refugees face when they came to Australia? **3**

ដោយយោលទៅលើសំដីរបស់លោកសាម តើអ្វីដែលជាបញ្ហា(ក្រៅពីភាសា)ចំពោះជនភៀសខ្លួនខ្មែរពេលគេមកដល់ប្រទេសអូស្ត្រាលី?

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

(b) What problems does Mr Sam say the parents now face? **2**

តើលោកសាមនិយាយថាបញ្ហាអ្វីដែលឪពុកម្តាយកំពុងប្រឈមមុខសព្វថ្ងៃ?

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

**End of Section 1**



www.theallpapers.com

**KHMER (CONTINUERS) EXAMINATION 2012**

**Section 1: Listening and Responding**

**PART A**

***Text 1***

[*Answering machine noises*]

ហេឡូ សុជាតិ! ខ្ញុំណារីណា! ខ្ញុំទូរស័ព្ទមកឯងដើម្បីប្រាប់ឯងថា ខ្ញុំដឹងក្រុមហ៊ុនមួយគេរកអ្នកចេះនិយាយភាសាខ្មែរនិងអង់គ្លេសស្ទាត់ជំនាញម្នាក់ដើម្បីទៅបកប្រែនៅមុខទស្សនិកជនក្នុងវគ្គសិក្សាមួយ។ ឯងអាចទូរស័ព្ទមកខ្ញុំបានបើឯងចាប់អារម្មណ៍ហើយចង់ដឹងពត៌មានបន្ថែមពីកិច្ចការនេះ។ លាហើយណា!។



www.theallpapers.com

***Text 2***

| | |
|---|---|
| ឪពុក | សារី! ម៉េចបានជាកូនឯងឆាប់ចូលទៅគេងម្ល៉េះយប់នេះ? ឯងមិនស្រួលខ្លួនអ្វី? |
| សារី | ទេប៉ា។ ខ្ញុំមានកិច្ចការធ្វើច្រើនណាស់ ហើយខ្ញុំដឹងថាខ្ញុំមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការទាំងអស់នោះទេ។ ដូច្នេះខ្ញុំគួរតែទៅដេកសិនចុះ! |
| ឪពុក | កុំឆ្កួត។ ឯងត្រូវតែខំសាកល្បងឱ្យអស់ពីសមត្ថភាព ហើយមិនត្រូវអស់សង្ឃឹមទេ។ |
| សារី | តើខ្ញុំត្រូវធ្វើយ៉ាងម៉េចទៅប៉ា? |
| ឪពុក | ឯងត្រូវតែមានគម្រោងសិក្សាល្អមួយហើយធ្វើតាមគម្រោងការនោះឱ្យបានហ្មត់ចត់។<br>ប៉ុន្តែឯងកុំភ្លេចដាក់បញ្ចូលពេលសម្រាកផង។<br>ឯងក៏ត្រូវតែញ៉ាំនិងគេងឱ្យបានគ្រប់គ្រាន់ផងដែរ។ |
| សារី | ខ្ញុំមានគម្រោងសិក្សាដែរ ប៉ុន្តែឥឡូវនេះខ្ញុំធ្វើមិនទាន់ទេ។ |
| ឪពុក | ម៉េចនឹងទាន់ បើឯងមិនធ្វើតាមគម្រោងការនោះផង។ ម្សិលមិញឯងថែមទាំងទៅមើលកុនជាមួយពួកម៉ាកផងមែនទេ? |
| សារី | មែនហើយប៉ា ខ្ញុំហាក់ដូចជាខ្ជីខ្ជាបន្តិចក្នុងរយៈពេលនេះ។ |
| ឪពុក | បើឯងមានបញ្ហានឹងមុខវិជ្ជាណាមួយ ប្រាប់ប៉ា ប៉ានឹងរកគ្រូជំនួយមកជួយឯង។<br>ម៉ាក់និងប៉ានឹងនៅកំដរឯងឱ្យបានយូរបន្តិចរាល់យប់។ ហើយប៉ានឹងសុំឱ្យម៉ាក់ឯងធ្វើម្ហូបដែលឯងចូលចិត្ត។ |
| សារី | អរគុណប៉ាណាស់! |



www.theallpapers.com

***Text 3***

[*Audience clapping at the* ***end*** *of the text*]

ខ្ញុំសូមណែនាំឱ្យស្គាល់កញ្ញាស្រី ចាន់ធីនិងក្រុមតន្ត្រីរបស់នាង។ រឿងរបស់កញ្ញាចាន់ធីធ្វើឱ្យយើងចាប់ចិត្តយ៉ាងខ្លាំង។ ក្នុងឋានៈជាស្ត្រីក្មេងម្នាក់
នាងបានចាកចេញពីភូមិកំណើតរបស់នាងដើម្បីទៅរកការងារធ្វើជាអ្នកចម្រៀងខារ៉ាអូខេដើម្បីតស៊ូទ្រទ្រង់ជីវិត។ នៅឆ្នាំ២០០៩នាងបានក្លាយជាអ្នកចម្រៀង
ឯកម្នាក់ក្នុងក្រុមតន្ត្រីមួយសម្តែងបទចម្រៀងពីឆ្នាំ១៩៦០ទៅ៧០។
បទចម្រៀងនាសម័យនោះរំលឹកប្រជាជនខ្មែរអំពីភាពសប្បាយរីករាយ
ហើយជាផ្នែកសំខាន់មួយសម្រាប់សម្គាល់លក្ខណៈភ្លេងនិងចម្រៀងខ្មែរ។
រយៈកាលនេះជារយៈកាលដ៏សន្តិភាពមួយក្នុងប្រវត្តសាស្ត្ររបស់ប្រទេសកម្ពុជា
ដែលប្រជាជនមានសេរីភាពក្នុងការបញ្ចេញគំនិតតាមរយៈបទចម្រៀងរបស់គេ។

សព្វថ្ងៃនេះ កញ្ញាចាន់ធីនិងក្រុមតន្ត្រីរបស់នាងជាអ្នកឈានមុខគេក្នុងការធ្វើឱ្យគេនិយមឡើងវិញនូវវប្បធម៌របស់ប្រទេសកម្ពុជា។ កញ្ញាចាន់ធីនឹងបង្ហាញ តាមរយៈបទចម្រៀងពិសេសនិងរបាំរបស់នាង ថាតើហេតុអ្វីបានជាវប្បធម៌សិល្បៈតន្ត្រីមានសារៈសំខាន់ក្នុងការកសាងសហគមន៍ឡើងវិញនិងបង្កើតសេចក្តីសង្ឃឹមសម្រាប់ប្រទេសកម្ពុជា។

សូមទស្សនិកជនទាំងអស់មេត្តាស្វាគមន៍កញ្ញាស្រី ចាន់ធីនិងក្រុមតន្ត្រីរបស់នាងបាទ!។

*Source*: Based on information in ‘Space Tripping’ with the Cambodian Space Project’,
www.cambodianallianceforthearts.com



www.theallpapers.com

***Text 4***

អ្នកសម្ភាស ថ្ងៃនេះខ្ញុំនឹងធ្វើការសម្ភាសជាមួយប្អូនប៊ុនថនដែលជាអ្នកលេងសៀកមានឈ្មោះល្បីម្នាក់។ សួស្តី ប៊ុនថន សុខសប្បាយទេ?

ប៊ុនថន ខ្ញុំសុខសប្បាយទេ អរគុណ។

អ្នកសម្ភាស ហេតុដូចម្តេចបានជាប្អូនសំរេចចិត្តចង់ធ្វើជាអ្នកលេងសៀក?

ប៊ុនថន ជាកុមារកំព្រាម្នាក់ ខ្ញុំគ្មានសមត្ថភាពទៅរៀននៅសាលាធម្មតាបានទេ។ ប៉ុន្តែជាសំណាងល្អដែលខ្ញុំដឹងថាខ្ញុំអាចចុះឈ្មោះចូលរៀននៅសាលាមួយបង្កើតដោយអង្គការហ្វារពន្លឺសិល្បៈ ដោយមិនបាច់បង់ថ្លៃ។ ខ្ញុំក៏ត្រូវបានគេទទួលឱ្យចូលរៀនក្នុងសាលាបង្ហាត់សៀកគ្រប់គ្រងដោយអង្គការដដែលនេះដែរ។
សាលានេះហើយដែលបានធ្វើឱ្យខ្ញុំដឹងថាខ្ញុំអាចក្លាយជាអ្នកសម្តែងសៀកបាន។
ឥឡូវណេះខ្ញុំជាតួឯកដ៏
សំខាន់ម្នាក់។

អ្នកសម្ភាស ល្អណាស់! តើហ្វារពន្លឺសិល្បៈជាអង្គការអ្វី?

ប៊ុនថន វាជាអង្គការមិនរកចំណេញមួយដែលផ្តល់នូវកិច្ចការសង្គម ការអប់រំនិងវប្បធម៌ដល់កុមារាកុមារីនិងគ្រួសាររបស់គេ។

អ្នកសម្ភាស តើអង្គការនេះបានទទួលថវិកាពីណាមក?

ប៊ុនថន អង្គការនេះបានទទួលថវិកាពីសប្បុរសជនជុំវិញពិភពលោក។ ម៉្យាងទៀតសាលានេះសម្តែងសិល្បៈសៀកពីរដងក្នុងមួយអាទិត្យជូនដល់ប្រជាជនដោយឥតគិតថ្លៃក្នុងគោលបំណងទាក់ទាញទស្សនិកជនឱ្យបានច្រើនបំផុត។
ប៉ុន្តែប្រជាជនក៏អាចធ្វើវិភាគទានបានដែរ។

អ្នកសម្ភាស ខ្ញុំបានឮពីទស្សនិកជនថាការសម្តែងសៀកនេះអស្ចារ្យណាស់ហើយឯងសម្តែងបានល្អមែនទែន!

ប៊ុនថន បាទ អរគុណ។

អ្នកសម្ភាស សូមឱ្យប្អូនមានសំណាងល្អទៅថ្ងៃមុខ។

*Source*: Based on information in www.phareps.org



www.theallpapers.com

**PART B**

***Text 5***

| | |
|---|---|
| ម្តាយ | សំណាង តើឯងធ្វើអីហ្នឹង? |
| សំណាង | ខ្ញុំសរសេរពាក្យសុំចុះឈ្មោះធ្វើការមិនពេញម៉ោងនៅភោជនីយដ្ឋានមួយ។ |
| ម្តាយ | ហ៊ឹម! ប៉ុន្តែម៉ាក់យល់ថាឯងគួរតែផ្ចង់គំនិតក្នុងការរៀនសូត្រវិញ ហើយកុំគិតពីរឿងប្រាក់កាសឱ្យសោះ។ តើឯងយល់ថា ម៉ាក់ឱ្យលុយឯងចាយមិនគ្រប់គ្រាន់អ្វីរាល់ថ្ងៃហ្នឹង? |
| សំណាង | ទេម៉ាក់។ ប៉ុន្តែម៉ាក់តែងតែរអ៊ូរទាំពេលបានឃើញថ្លៃទូរស័ព្ទដៃខ្ញុំម្តងៗ។ បើសិនជាខ្ញុំមានការងារធ្វើបន្តិចបន្តួច ខ្ញុំអាចបង់ថ្លៃទូរស័ព្ទរបស់ខ្ញុំបាន។ |
| ម្តាយ | មើល! ម៉ាក់អាចមើលពាក្យសុំធ្វើការរបស់ឯងបន្តិចបានទេ? |
| សំណាង | មានអីម៉ាក់។ |
| ម្តាយ | ហេតុដូចម្តេចបានជាឯងសរសេរល្អៗច្រើនពីខ្លួនឯងខ្លាំងម្ល៉េះ? ដូចជាអួតខ្លួនឯងខ្លាំងពេកហើយ។ មិនខ្មាស់គេទេអ្វី? សុភាសិតថែងថា "កុំអង្គុយលើចង្អេរហើយលើកខ្លួនឯង។ |
| សំណាង | ម៉ាក់! នៅប្រទេសអូស្ត្រាលី ក្នុងការដាក់ពាក្យសុំធ្វើការ គេត្រូវតែចេះលក់ខ្លួនឯងដល់ចៅហ្វាយនាយអញ្ចឹងហើយ។ |
| ម្តាយ | ម៉ាក់ដឹងហើយ ប៉ុន្តែនេះវាដូចជាជ្រុលពេកតាមម៉ាក់យល់។ តើឯងអាចកែពាក្យសុំបន្តិចបានទេមុននឹងផ្ញើទៅ? |
| សំណាង | បាទ អញ្ចឹងចាំខ្ញុំកែចេញបន្តិចចុំះ។ |



www.theallpapers.com

***Text 6***

អ្នកសម្ភាស ថ្ងៃនេះខ្ញុំនឹងធ្វើការសម្ភាសជាមួយលោកសាម ប្រធានសមាគមខ្មែរ។ ជំរាបសួរ។

លោកសាម បាទ ជំរាបសួរ។

អ្នកសម្ភាស កាលពីជនភៀសខ្លួនខ្មែរយើងទើបមកដល់ប្រទេសអូស្ត្រាលីដំបូង តើគាត់មានវិបត្តិ ឬបញ្ហាអ្វីខ្លះក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់?

លោកសាម បញ្ហាធំចម្បងរបស់គាត់គឺបញ្ហាភាសា។ គាត់មានការពិបាកក្នុងការទាក់ទងជាមួយ ជនជាតិអូស្ត្រាលី។

អ្នកសម្ភាស តើគាត់ជួបប្រទះនឹងបញ្ហាអ្វីទៀតដែរ?

លោកសាម គាត់មានការយល់ដឹងតិចតួចពីទំនៀមទំលាប់និងច្បាប់របស់ប្រទេសអូស្ត្រាលី ដែលជាហេតុធ្វើអោយគាត់ខ្លាចអាជ្ញាធរ។ ទំនាស់ខាងផ្នែកវប្បធម៌រវាងឪពុកម្តាយ និងកូនចៅច្រើនកើតមានឡើងក្នុងសហគមន៍ខ្មែរ។ កូនចៅច្រើនតែមិនយល់ឬមិន ឱ្យតម្លៃដល់សេចក្តីស្រឡាញ់របស់ឪពុកម្តាយរបស់ខ្លួនទេ។

អ្នកសម្ភាស តើឪពុកម្តាយមានជួបប្រទះនឹងបញ្ហាអ្វីផ្សេងទៀតទេ?

លោកសាម បាទមាន ឪពុកម្តាយធ្លាប់ធ្វើការដោយប្រើកំឡាំងកាយយ៉ាងលំបាកដើម្បីផ្គត់ផ្គង់ គ្រួសារ ព្រោះគាត់មករស់នៅទីនេះដោយបាទដៃទទេហើយមានរបស់របរតែបន្តិច បន្តួច។ ការមានផ្ទះមួយខ្លួនឯងនិងការសិក្សាដ៏ល្អរបស់កូនចៅជាគោលបំណង ចម្បងរបស់គាត់។

អ្នកសម្ភាស ចុះសព្វថ្ងៃនេះ គាត់មានបញ្ហាអ្វីទេ?

លោកសាម បាទ ៣០ឆ្នាំបានកន្លងផុតទៅហើយ។ ជីវភាពរបស់គាត់ប្រសើរមែនទែន។ បញ្ហាធំចម្បងដែលគាត់ប្រឈមមុខគឺសុខភាព។ អ្នកខ្លះឈឺខ្នង កដៃ ដៃនិងជើង ពីព្រោះគាត់ធ្លាប់បានធ្វើការហួសកម្លាំងពីមុនមក រួមផ្សំជាមួយនិងភាពចាស់ជរា របស់គាត់។ គាត់បារម្ភថាតើអ្នកណានឹងថែរក្សាគាត់ទៅថ្ងៃមុខ ពីព្រោះគាត់មិនចង់ ទៅរស់នៅក្នុងមណ្ឌលចាស់ជរាទេ។

អ្នកសម្ភាស សូមអរគុណលោកប្រធាន។



www.theallpapers.com

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2012 Public Examination

# Khmer

## Continuers Level

## Section 2: Reading and Responding (30 marks)

**Instructions to Students**

1. Allow approximately 1 hour and 15 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet in blue or black ink or ball-point pen.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2012

www.theallpapers.com

**Part A** (Questions 7 to 8)
(20 marks)

---

*When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:*

- *understand general and/or specific aspects of texts, by, for example, comparing, contrasting, summarising, or evaluating, and convey the information accurately and appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

ព្រៃវែង ទី១៦ មេសា ២០១២

ជំរាបមកលោកឪពុកអ្នកម្ដាយជាទីនឹករលឹកបំផុត!

តើលោកឪពុកអ្នកម្ដាយសុខសប្បាយទេ? ខ្ញុំសង្ឃឹមថាលោកទាំងពីរសុខសប្បាយជាធម្មតាទេ។

ខ្ញុំបានមកស្នាក់នៅភូមិយើងក្នុងផ្ទះលោកពូជូនអស់រយៈពេលមួយអាទិត្យហើយ។ ធាតុអាកាសល្អឥតខ្ចោះ ឯខ្យល់ក៏បរិសុទ្ធដែរ។ អ្នកភូមិដើរទៅផ្សាររាល់ព្រឹកដើម្បីទិញចំណីអាហារ។ ទីនេះគ្មានអគ្គីសនីទេ ដូច្នេះគ្មានទូទឹកកកសម្រាប់រក្សាចំណីឱ្យនៅស្រស់បានឡើយ។ អ្នកភូមិនៅទីនេះស៊ាំអស់ហើយ ប៉ុន្តែខ្ញុំសង្ស័យថាខ្ញុំមិនអាចរស់នៅដោយគ្មានអគ្គីសនីបានយូរទេ។

ទីនេះក៏គ្មានភោជនីយដ្ឋានដែរ ដូច្នេះហើយបានជាអ្នកស្រុកធ្វើម្ហូបល្អៗដោយខ្លួនឯងសម្រាប់គ្រួសារគេរាល់ថ្ងៃ។ អាហារគ្រប់មុខសុទ្ធតែស្រស់ៗហើយមានរសជាតិឆ្ងាញ់ណាស់។ ខ្ញុំមានកម្លាំងនិងសុខភាពមាំមួនពីព្រោះខ្ញុំញ៉ាំតែម្ហូបល្អៗ ប៉ុន្តែខ្ញុំនៅតែនឹកដល់ចំណីខ្លះដែលខ្ញុំចូលចិត្ត។ តើខ្ញុំអាចនៅបន្តបានយូរប៉ុនណាដោយអត់បានញ៉ាំហែមប័រហ្គ័រ?

ប្អូនជីដូនមួយខ្ញុំដើរទៅដើរមកខ្លួនឯងពីសាលារៀនដែលឋិតនៅចម្ងាយមួយគីឡូម៉ែត្រពីផ្ទះដោយគ្មានព្រួយបារម្ភអំពីភាពគ្រោះថ្នាក់ឡើយ។ វាបានប្រាប់ខ្ញុំថា លោកគ្រូវាស្គាល់គ្រួសារទាំងអស់ក្នុងភូមិ។ នេះបញ្ជាក់អំពីភាពរាក់ទាក់និងជិតដិតរវាងគ្នានិងគ្នាក្នុងសហគមន៍។

ជីវិតនៅក្នុងភូមិងាយស្រួលហើយមានសុវត្ថិភាពល្អណាស់។ ភាគច្រើនអ្នកភូមិដើរទៅធ្វើស្រែចម្ងាយប្រហែលមួយឬពីរគីឡូម៉ែត្រពីផ្ទះ។ គេធ្វើការរាល់ថ្ងៃ គ្មានថ្ងៃសម្រាកទេ លើកលែងតែថ្ងៃបុណ្យខ្លះដូចជាបុណ្យចូលឆ្នាំខ្មែរជាដើម។ តើខ្ញុំអាចរស់នៅតាមរបៀបនេះបានទេ?

ខ្ញុំស្រឡាញ់ទីនេះណាស់ ប៉ុន្តែខ្ញុំដឹងថាខ្ញុំមិនអាចរស់នៅទីនេះរហូតបានទេ។ ខ្ញុំនឹកលោកឪពុកអ្នកម្ដាយខ្លាំងណាស់ហើយទន្ទឹងរង់ចាំត្រឡប់មកផ្ទះវិញ។

ដោយក្ដីរឭកនិងស្រឡាញ់

ពីកូនសម្លាញ់
វីណា



www.theallpapers.com

QUESTIONS

**Marks**

(a) What does Rina like about living in the village? **5**



www.theallpapers.com

**Marks**

(b) What aspects of life in the village would Rina find challenging over time? **4**

(c) What words and expressions does Rina use to convey his views? **4**



www.theallpapers.com

This page is intentionally blank





www.theallpapers.com

8. Read the text and then answer in ENGLISH the questions that follow.

ពេលដែលខ្ញុំចាកចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ទីក្រុងនេះជាទីក្រុងមួយដែលធ្លាប់មានឈ្មោះល្បីល្បាញថាជាទីក្រុងដ៏ស្អាតហើយមានសណ្តាប់ធ្នាប់ត្រឹមត្រូវល្អណាស់។ កាលណោះទីក្រុងភ្នំពេញមានប្រជាជនចំនួនត្រឹមតែកន្លះលាននាក់ប៉ុណ្ណោះ។ មនុស្សភាគច្រើនធ្វើដំណើរដោយថ្មើរជើង ជិះកង់ ជិះស៊ីក្លូឬជិះម៉ូតូទៅធ្វើការ។ គ្រួសារភាគតិចណាស់ដែលមានសមត្ថភាពទិញរថយន្តជិះ។ កត្តាទាំងអស់នេះហើយដែលធ្វើអោយចរាចរណ៍នៅទីក្រុងភ្នំពេញមានសភាពងាយស្រួល។ ប៉ុន្តែកត្តាចម្បងនោះគឺប្រជាជនភាគច្រើនមិនថាអ្នកមាន អ្នកក្រឬអ្នកមានបុណ្យសក្តិទេសុទ្ធតែឱ្យតម្លៃនិងគោរពដល់អាជ្ញាធរទាំងអស់គ្នា។

ចំណាប់អារម្មណ៍របស់ខ្ញុំជាលើកដំបូងពេលដែលខ្ញុំបានត្រឡប់មកដល់ទីក្រុងភ្នំពេញភ្លាមកាលពីខែមុន ក្រោយពីបានចាកចេញពីទីក្រុងនេះអស់រយៈពេលជិត៤០ឆ្នាំមក គឺទីក្រុងនេះមានសភាពអ៊ូអរជាងមុនឆ្ងាយណាស់។ នេះគឺដោយសារតែចំនួនប្រជាជនបានកើនឡើងដល់ទៅជិតមួយលានប្រាំពីរសែននាក់ឯណោះ។ ទិដ្ឋភាពនៃអាគារធំៗស្អាតៗនិងសំណង់ខ្ពស់ៗដុះរីកដូចផ្សិត ព្រមជាមួយនិងរថយន្តនិងម៉ូតូគ្រប់ធុនរត់នៅលើផ្លូវ បញ្ជាក់អោយខ្ញុំដឹងថា ជីវភាពប្រជាជននៅទីក្រុងភ្នំពេញសព្វថ្ងៃនេះមានកំរិតខ្ពស់ជាងកាលពីសម័យមុនឆ្ងាយណាស់ ដែលខ្ញុំគួរតែកោតសរសើរ។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមក ខ្ញុំមានការស្រងាកចិត្តជាខ្លាំងដោយបានជួបប្រទះនឹងការស្ទះចរាចរណ៍។ មានកត្តាជាច្រើនដែលរួមចំណែកក្នុងបញ្ហានេះ ម៉្យាងមកពីផ្លូវមានទំហំតូចពេកសម្រាប់ចំនួនយានជំនិះសព្វថ្ងៃ។ ម៉្យាងទៀតប្រជាជនមិនគោរពច្បាប់ចរាចរណ៍ រួមជាមួយនិងអ្នកជំនួញខ្លះប្រកបរបររកស៊ីនៅពេញលើចិញ្ចើមថ្នល់សម្រាប់ដើរទាំងស្រុង ហើយអ្នកលក់ខ្លះទៀតថែមទាំងតាំងរបស់របរលក់នៅលើថ្នល់ទៀតផង។

រាជរដ្ឋាភិបាលកម្ពុជាកំពុងដោះស្រាយបញ្ហានេះដោយសាងសង់វិថីថែមទៀត។ កិច្ចការនេះមិនអាចធ្វើបានភ្លាមៗទេ។ ទន្ទឹមនឹងនេះ បញ្ហាស្ទះចរាចរណ៍នឹងបានប្រសើរឡើងបើសិនជាប្រជាជនគ្រប់រូបនាំគ្នាគោរពច្បាប់ចរាចរណ៍។

អ្នកនិពន្ធ: សូផារី កែវ
មីនា២០១២

QUESTIONS

**Marks**

(a) Write an appropriate title for this article. **1**

___

___

___



www.theallpapers.com

**Marks**

(b) What was Sophary's first impression of Phnom Penh when she returned to the city? **2**

(c) What reasons does Sophary give for the difference in traffic flow between 1975 and 2012? **4**



www.theallpapers.com

**Part B** (Question 9)
(10 marks)

---

*When judging performance in this part, the examiner(s) will take into account the extent to which the student demonstrates the capacity to:*

- *understand general and specific aspects of a text by identifying, analysing, and responding to information;*
- *convey information coherently (structure, sequence, accuracy and variety of vocabulary and sentence structure) and appropriately (relevance, use of conventions of the text type).*

---

9. Read the text and then answer the question below in 150 to 200 words in KHMER.

This text cannot be reproduced here for copyright reasons.

*Source*: Based on www.tourismcambodia.org

QUESTION

You attended the event advertised above and have been given an opportunity to express your views about it on a Cambodian tourism website. You have decided to write an article in which you describe your experiences at the event and evaluate its success. Write your article.

អ្នកបានចូលរួមកំសាន្តក្នុងពិធីបុណ្យដូចបានពណ៌នាក្នុងការផ្សាយខាងលើ ហើយបានទទួលឱកាសក្នុងការបញ្ចេញទស្សនៈរបស់អ្នកអំពីពិធីនេះដាក់ក្នុងវ៉ិបសាយទេសចរណ៍ខ្មែរ។ អ្នកបានសម្រេចចិត្តសរសេរអត្ថបទសម្រាប់ចុះផ្សាយមួយដោយរៀបរាប់អំពីបទពិសោធន៍របស់អ្នកក្នុងពិធីបុណ្យ និងធ្វើការវាយតម្លៃលើការជោគជ័យនៃពិធីបុណ្យនេះ។ ចូរអ្នកសរសេរអត្ថបទសម្រាប់ចុះផ្សាយនោះ។



www.theallpapers.com

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.





www.theallpapers.com

This page is intentionally blank



www.theallpapers.com

Question 9





www.theallpapers.com

**End of Section 2**



www.theallpapers.com

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

## 2012 Public Examination

# Khmer

## Continuers Level

## Section 3: Writing in Khmer (15 marks)

**Instructions to Students**

1. Allow approximately 45 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet in blue or black ink or ball-point pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2012

www.theallpapers.com

**Section 3** (Questions 10 to 11)
(15 marks)

---

*When judging performance in this section, the examiner(s) will take into account the extent to which the student demonstrates:*

- *relevance and depth of treatment of ideas, information, or opinions;*
- *accuracy and range of vocabulary and sentence structures;*
- *the capacity to structure and sequence response and capacity to use conventions of the text type.*

---

Answer ONE question from this section in 200 to 250 words in KHMER.

10. Write the text of a talk that you will give to your class on how the role of Khmer women in Australia has changed over the years, based on your own observations.

    ចូរអ្នកសរសេរអត្ថបទសម្រាប់និយាយក្នុងថ្នាក់របស់អ្នកមួយ ដោយធ្វើការរៀបរាប់អំពីការផ្លាស់ប្តូរនៃមុខងារស្ត្រីខ្មែរនៅប្រទេសអូស្ត្រាលីក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងទៅនេះ យោលទៅតាមការសង្កេតរបស់អ្នកផ្ទាល់។

11. Your uncle from Cambodia is planning to visit Australia for 2 weeks during the next school holidays. Your family decided to invite him to stay with them and to take him to visit a number of places that show Australian culture. Your mother has asked you to write a letter to your uncle letting him know about the invitation and the plan for hosting him. Write your letter.

    ឪពុកមារបស់អ្នកនៅប្រទេសកម្ពុជាមានគម្រោងមកទស្សនាប្រទេសអូស្ត្រាលីចំនួនពីរសប្តាហ៍ក្នុងពេលវិស្សមកាលសាលាខាងមុខនេះ។ គ្រួសាររបស់អ្នកបានសម្រេចចិត្តថានឹងទទួលឪពុកមារបស់អ្នកឱ្យស្នាក់នៅក្នុងផ្ទះអ្នក និងជួយដឹកនាំទៅកំសាន្តកន្លែងនានាដែលបង្ហាញពីវប្បធម៌របស់ប្រទេសអូស្ត្រាលី។ ម្តាយរបស់អ្នកបានសុំឱ្យអ្នកសរសេរសំបុត្រទៅឪពុកមារបស់អ្នក ដោយរៀបរាប់អំពីសេចក្តីអញ្ជើញនិងគម្រោងការទទួលគាត់របស់គ្រួសារអ្នក។ ចូរអ្នកសរសេរសំបុត្ររបស់អ្នក។



www.theallpapers.com

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.



PLEASE TURN OVER

www.theallpapers.com

This page is intentionally blank



www.theallpapers.com

Question Number:





www.theallpapers.com

www.theallpapers.com

**End of Section 3**



www.theallpapers.com